ធនាគារជាតិ នៃ កម្ពុជា

លេខ..............................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទវគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋាន ស្តីពី "ការត្រួតពិនិត្យធនាគារ"
## ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ នៅធនាគារជាតិនៃកម្ពុជា

**ឯកឧត្តម លោក លោកស្រី គ្រូឧទ្ទេសនាម និងក្មួយៗសិក្ខាកាមទាំងអស់ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីរំភើបសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមជាមួយ ឯកឧត្តម លោក លោកស្រី គ្រូឧទ្ទេសនាម និងក្មួយៗ ក្នុងពិធីបិទវគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋាន ស្តីពី "ការត្រួតពិនិត្យធនាគារ" នាវេលារសៀលនេះ ដែលខ្ញុំបានប្រសិទ្ធនាមវគ្គបណ្តុះបណ្តាលលើកដំបូងនេះថាជាវគ្គ "បាគង" ដែលតំណាងឲ្យការចាប់ ផ្តើមនៃដំណាក់កាលសុខសន្តិភាព ឯកភាពជាតិ ភាពរុងរឿង រីកចម្រើន និងវឌ្ឍនភាព ។ វគ្គបាគង យើងប្រព្រឹត្តទៅអស់រយៈពេលពីរសប្តាហ៍ បានផ្តល់ឱកាសដ៏វិសេសសម្រាប់ឲ្យសិក្ខាកាមបាន សិក្សាស្វែងយល់ និងក្រេបយកចំណេះដឹង និងបទពិសោធន៍ល្អៗពីគ្រូឧទ្ទេសនាម ទាំងផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែង ជាពិសេស ការបែងចែកជាក្រុមពិភាក្សាដើម្បីផ្លាស់ប្តូរទស្សនៈ យោបល់ និងរៀនសូត្រពីគ្នាទៅវិញទៅមកយ៉ាងសកម្ម ពិតជាធ្វើឲ្យសិក្ខាកាមទាំងអស់ ជាពិសេសមន្ត្រី ត្រួតពិនិត្យបានពង្រឹង និងធ្វើបច្ចុប្បន្នកម្មចំណេះដឹងរបស់ខ្លួនបន្ថែមទៀត ស្របទៅតាមការអភិវឌ្ឍរីកចម្រើននៃវិស័យធនាគារ ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចជាតិទាំងមូល ។

ជារួម ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅដោយរលូន រហូតដល់ទីបញ្ចប់ប្រកបដោយជោគជ័យ ។ ខ្ញុំជឿជាក់ថា លោក លោកស្រី និងក្មួយៗទាំងអស់ ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ពិតជាក្តាប់បាននូវខ្លឹមសាររួមនៃការវិវត្តរីកចម្រើនថ្មីៗនៃប្រព័ន្ធហិរញ្ញវត្ថុទាំងមូល ក៏ដូចជាការវិវត្ត និងប្រែប្រួលឥតឈប់ឈរនៃវិស័យធនាគារ បទប្បញ្ញត្តិ ការគ្រប់គ្រងហានិភ័យ ផលិតផលហិរញ្ញវត្ថុ និងយន្តការនៃការត្រួតពិនិត្យ តាមរយៈបទពិសោធន៍ ទ្រឹស្តីថ្មីៗ និងអនុសាសន៍ផ្សេងៗ ដែលគ្រូឧទ្ទេសនាមរបស់យើងបានជម្រាបជូន ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដល់អស់លោក លោកស្រី ជាគ្រូឧទ្ទេសនាម ទាំងអស់ដែលបានចូលរួមយ៉ាងសកម្មក្នុងការណែនាំ ពន្យល់ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ហើយក៏សូមថ្លែងអំណរគុណផងដែរចំពោះលោក លោកស្រី និងក្មួយៗទាំងអស់ដែលបានខិតខំយកចិត្តទុកដាក់ស្តាប់បទឧទ្ទេសនាម និងមានវត្តមាននៅទីនេះតាំងពីដើមដល់ចប់ ។

**ឯកឧត្តម លោក លោកស្រី គ្រូឧទ្ទេសនាម និងក្មួយៗសិក្ខាកាមទាំងអស់ជាទីមេត្រី!**

ធនធានមនុស្ស ក្រៅពីកាយសម្បទាជារូបវន្ត គឺផ្តោតសំខាន់ទៅលើទ្រព្យបញ្ញា (Intellectual assets) របស់ពលករជំនាញ (Qualified manpower) អ្នកគ្រប់គ្រង (Manager) អ្នករៀបចំយុទ្ធសាស្ត្រ (Strategist) អ្នកសម្របសម្រួល (Facilitator) និងអ្នកដឹកនាំនយោបាយ (Political leader) របស់អង្គភាព ប្រព័ន្ធ ឬប្រជាជាតិមួយ ដែលជាអ្នកធ្វើឲ្យដំណើរការអង្គភាព ប្រព័ន្ធ ឬប្រទេសនោះ ឲ្យប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និងចំគោលដៅ ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព ។

ការអភិវឌ្ឍធនធានមនុស្សគឺជាគន្លឹះក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិ ។ ការអភិវឌ្ឍធនធានមនុស្សគឺត្រូវបណ្តុះបណ្តាលផ្នែកកម្លាំងកាយ និងកម្លាំងប្រាជ្ញា-ស្មារតី ។ ការអភិវឌ្ឍកម្លាំងប្រាជ្ញា-ស្មារតី គឺបណ្តុះបណ្តាលចំណេះដឹងផ្នែកទ្រឹស្តី និងការអនុវត្ត (IQ) ព្រមទាំងសីលធម៌ និងចរិយាធម៌ (EQ) ។ ការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយប្រសិទ្ធភាពគឺអាស្រ័យលើការគ្រប់គ្រង និងការចាត់ចែងធនធានមនុស្សបានល្អ ស្របតាមជំនាញ និងសមត្ថភាព ។ មានធនធានមនុស្ស គួបផ្សំនឹងធនធានធម្មជាតិ និងស្ថិរភាពនយោបាយ ប្រទេសជាតិនឹងមានការអភិវឌ្ឍ ។ ដូច្នេះ ការអភិវឌ្ឍធនធានមនុស្ស គឺជាយន្តការអាទិភាពមួយដែលធនាគារជាតិនៃកម្ពុជាតែងតែយកចិត្តទុកដាក់ជាប់ជាប្រចាំតាមគ្រប់រូបភាព ពិសេស គឺដើម្បីបន្តពង្រឹងប្រព័ន្ធធនាគារ ក៏ដូចជាបណ្តាធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗដែលនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជាឲ្យរឹងមាំ មានសុខភាពល្អ និងមានប្រសិទ្ធភាព ប្រកបដោយជំនឿទុកចិត្តខ្ពស់ពីសាធារណជន ស្របតាមសភាពការណ៍វិវត្តន៍នៃសេដ្ឋកិច្ច ខណៈដែលកម្ពុជាកំពុងខិតខំអភិវឌ្ឍខ្លួនដើម្បីធ្វើសមាហរណកម្មចូលក្នុងតំបន់ និងពិភពលោក ។

**ឯកឧត្តម លោក លោកស្រី គ្រូឧទ្ទេសនាម និងក្មួយៗសិក្ខាកាមទាំងអស់ជាទីមេត្រី!**

គោលដៅរយៈពេលវែងរបស់យើងក្នុងការបណ្តុះបណ្តាលធនធានមនុស្ស លើផ្នែកត្រួតពិនិត្យធនាគារនេះ គឺជំនាញភាវូបនីយកម្ម (Specialization) ពោលគឺពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យឲ្យច្បាស់លាស់ និងទូលំទូលាយ សំដៅរួមចំណែកជួយពង្រឹងស្ថិរភាពប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ និងសុខភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឲ្យរឹងមាំប្រកបដោយជំនឿទុកចិត្ត ដែលជាប្រេងរំអិលជួយគៀងគរធនធានសម្រាប់ការវិនិយោគ និងធុរកិច្ច សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល គឺ កំណើនការងារ សមធម៌ និងប្រសិទ្ធភាព ។ គោលដៅរយៈកាលខ្លីនិងមធ្យមរបស់យើង គឺត្រូវបន្តជំរុញ

ការបណ្តុះបណ្តាលមន្ត្រីជំនាញគ្រប់ផ្នែក ពិសេស ដែលយើងកំពុងធ្វើនៅពេលនេះគឺផ្នែកត្រួតពិនិត្យធនាគារ មិនត្រឹមតែលើខាងជំនាញទ្រឹស្តី និងការអនុវត្តជាក់ស្តែងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងខាងវិន័យសីលធម៌ ភាពស្មោះត្រង់ និងសេចក្តីថ្លៃថ្នូរក្នុងពេលបំពេញការងាររបស់មន្ត្រីនោះទៀតផង ។ ទៅអនាគត យើងនឹងបន្តបើកវគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋានផ្នែកត្រួតពិនិត្យធនាគារនៅធនាគារជាតិនៃកម្ពុជាយើង សម្រាប់មន្ត្រីក្មេងៗ ជាបន្តបន្ទាប់ទៀត ។

សមត្ថភាពបំពេញការងារគឺជាគ្រឹះក្នុងការសម្រេចភារកិច្ចប្រកបដោយជោគជ័យ ។ ចំណេះវិជ្ជាដែលយើងទទួលបានគឺជាប្រទីបបំភ្លឺទិសដៅទៅអនាគត ។ ឯការសម្រេចបានបំណងប្រាថ្នាទៅអនាគត គឺអាស្រ័យទៅលើការតស៊ូ ការខិតខំប្រឹងប្រែង និងការលះបង់របស់បុគ្គលនោះ ។ ដូចពាក្យចាស់លោកបានពោលថា "ប្រាជ្ញាបុណ្យផងកើតដោយប្រតិបត្តិ" មានន័យថា ប្រាជ្ញាក្តី បុណ្យក្តី កើតមានអាស្រ័យលើសេចក្តីប្រតិបត្តិលើការរៀន ស្តាប់ គិត សួរ និងកត់ត្រាតាមគោលការណ៍ព្រះសម្មាសម្ពុទ្ធទាំងបួនគឺ សុ ចិ បុ លិ ចំណែកឯបុណ្យកើតមានអាស្រ័យលើការកសាងនូវបុញ្ញកិរិយាវត្ថុទាំង១០ *(គឺ ១- ទានមយៈ បុណ្យកើតមានព្រោះការឲ្យទាន, ២- សីលមយៈ ព្រោះការរក្សាសីល, ៣- ភាវនាមយៈ ព្រោះការរីកចម្រើនធម៌ដែលគួរចម្រើន ឲ្យកើតមានក្នុងចិត្ត, ៤- អបចាយនមយៈ ព្រោះការគោរពកោតក្រែងឱនលំទោន ជឿស្តាប់បុគ្គលគួរគោរព, ៥- វេយ្យាវច្ចមយៈ ព្រោះការខ្នះខ្នែងខ្វល់ខ្វាយចាត់កិច្ចការបុណ្យ ឬបម្រើក្នុងការធ្វើបុណ្យ, ៦- ធម្មទេសនាមយៈ ព្រោះការសម្តែងឬពន្យល់ធម៌ឲ្យគេស្គាល់ឬបង្រៀនឲ្យគេចេះធម៌ផង ៧- ធម្មស្សវនមយៈ ព្រោះការស្តាប់ធម៌ដោយគោរព គឺស្តាប់ដោយយកចិត្តទុកដាក់ ៨- បត្តិទានមយៈ ព្រោះការឲ្យចំណែកបុណ្យ គឺជូនឬឧទ្ទិសចំណែកបុណ្យដែលខ្លួនបានហើយឲ្យទៅអ្នកដទៃ ៩- បត្តានុមោទនាមយៈ ព្រោះការត្រេកអរទទួលយកចំណែកបុណ្យដែលគេឲ្យមកខ្លួន ១០- ទិដ្ឋុជុកម្មមយៈ ព្រោះការធ្វើសេចក្តីយល់ឃើញរបស់ខ្លួនឲ្យត្រូវត្រង់តាមផ្លូវពិត គឺធ្វើប្រាជ្ញាជាសម្មាទិដ្ឋិឲ្យកើតមានក្នុងសន្តានចិត្ត)* ។

បុគ្គលទាំងឡាយណាដែលប្រកាន់ខ្ជាប់នូវគោលការណ៍ទាំងនេះ គឺជាបុគ្គលដែលសម្បូរទៅដោយពុទ្ធិក្នុងការគ្រប់គ្រងជីវិត និងដោះស្រាយការងារដោយជោគជ័យ ហើយសូមឲ្យលោក លោកស្រី និងក្មួយៗទាំងអស់ ដែលបានទទួលចំណេះដឹង និងបទពិសោធន៍ពីមន្ត្រីឧទ្ទេសនាមរបស់យើង យកចំណេះដឹងទាំងនេះទៅធ្វើជាគោល ដើម្បីទៅក្រេបយកចំណេះដឹងថ្មីៗទៀត និងទៅអនុវត្តការងាររបស់ខ្លួនដោយប្រុងប្រយ័ត្ន ឲ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ ។

ដូច្នេះជាទិសដៅទៅអនាគត យើងនឹងបន្តរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងធនាគារជាតិនៃកម្ពុជាយើងឲ្យបានទៀងទាត់ជាប់ជាប្រចាំ និងខិតខំកែលម្អវគ្គនីមួយៗឲ្យកាន់តែប្រសើរឡើងឥតឈប់ឈរ ទាំងលើកម្មវិធី និងលើខ្លឹមសារ ដើម្បីឲ្យវគ្គបណ្តុះបណ្តាលផ្ទៃក្នុងរបស់

យើងមានលក្ខណៈល្អប្រកបដោយគុណភាពខ្ពស់ ដូចនៅបណ្តាធនាគារកណ្តាលផ្សេងទៀត នៅក្នុងតំបន់ និងពិភពលោក ។ ម្យ៉ាងទៀត នៅចុងបញ្ចប់វគ្គបណ្តុះបណ្តាលនីមួយៗ គឺមានការធ្វើតេស្តប្រលង និងមានការវាយតម្លៃទាំងលើការបង្រៀនរបស់គ្រូឧទ្ទេសនាម ទាំងលើការយល់ដឹងរបស់សិក្ខាកាមផងដែរ ។ លទ្ធផលនៃការសិក្សារបស់សិក្ខាកាមគឺជាមូលដ្ឋានសម្រាប់ឲ្យថ្នាក់ដឹកនាំប្រើជាលក្ខខ័ណ្ឌវិនិច្ឆ័យមួយក្នុងការប្រគល់តួនាទី ភារកិច្ច និងមុខតំណែង ក៏ដូចជាការលើកទឹកចិត្តផ្សេងៗ ជាសម្ភារៈក្តី ជាស្មារតីក្តី ឲ្យស្របតាមសមត្ថភាព និងការយល់ដឹងរបស់មន្ត្រីម្នាក់ៗ ។

**ឯកឧត្តម លោក លោកស្រី គ្រូឧទ្ទេសនាម និងក្មួយៗសិក្ខាកាមទាំងអស់ជាទីមេត្រី!**

ដើម្បីឲ្យចំណេះដឹងរបស់យើងកាន់តែរីកចម្រើន និងមានប្រយោជន៍ចំពោះការងារប្រចាំថ្ងៃថែមទៀត ខ្ញុំសូមផ្តាំផ្ញើដល់លោក លោកស្រី គ្រូឧទ្ទេសនាម និងក្មួយៗទាំងអស់ នូវពាក្យពេចន៍មួយចំនួន ដូចតទៅ ៖

- ត្រូវបន្តដុសខាត់ចំណេះដឹងរបស់ខ្លួនបន្ថែមទៀត តាមរយៈការអានសៀវភៅជាប់ជាប្រចាំ ការសិក្សាស្រាវជ្រាវ ការធ្វើស្វ័យសិក្សា និងដកស្រង់ ឬផ្លាស់ប្តូរបទពិសោធន៍ជាមួយរៀមច្បងនៅកន្លែងធ្វើការ ឬតាមរយៈការចូលរួមសិក្ខាសាលាផ្សេងៗជាដើម បន្ទាប់ពីបានបញ្ចប់ការសិក្សានៅទីនេះ ដូចពាក្យបុរាណពោលថា "តក់ៗពេញបំពង់" ។

- ត្រូវបង្កើនចំណេះដឹងផ្នែកកុំព្យូទ័រ និងភាសាបរទេស ដូចជា អង់គ្លេស បារាំង ឬភាសាផ្សេងទៀត ដែលជាស្ពានមួយយ៉ាងសំខាន់សម្រាប់ការងារជាតិ និងអន្តរជាតិ ខណៈដែលប្រទេសកម្ពុជាយើងកំពុងធ្វើសមាហរណកម្មសេដ្ឋកិច្ចចូលទៅក្នុងតំបន់ និងពិភពលោក ។

- ត្រូវយកចំណេះដឹងដែលយើងមាន ទៅប្រើប្រាស់បម្រើប្រយោជន៍ការងារប្រចាំថ្ងៃឲ្យចំទិសដៅ និងមានប្រសិទ្ធភាព ។ បុគ្គលដែលមានចំណេះដឹងទាំងនេះហើយ ដើម្បីឲ្យជីវិតនិងការងាររបស់ខ្លួនកាន់តែទទួលបានជោគជ័យបន្ថែមទៀត ត្រូវមានសីលធម៌និងគុណធម៌ មានភាពអំណត់និងស្មោះត្រង់ ហើយប្រកាន់ខ្ជាប់នូវវិន័យការងារ ដែលជាកត្តាមិនអាចខ្វះបានសម្រាប់កំណត់ជ័យជម្នះ ។

ជាទីបញ្ចប់ ឆ្លៀតឱកាសដែលប្រជាជនយើងទាំងអស់គ្នាបានប្រារព្ធពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៦ ដែលកន្លងទៅកាលពីពេលថ្មីៗនេះ ខ្ញុំសូមជូនពរដល់ ឯកឧត្តម អស់លោក លោកស្រី និងក្មួយៗទាំងអស់ ដែលមានវត្តមាននៅទីនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទវគ្គបណ្តុះបណ្តាល " វគ្គបាគង " ដែលបានបញ្ចប់ដោយជោគជ័យជាស្ថាពរ ។**

**សូមអរគុណ!**